# ដំណោះស្រាយក្នុងការបោះឆ្នោតសំរាប់ពលរដ្ឋគ្រប់រូប

## លទ្ធភាពចេញចូល

ការរៀបចំបង្កើតឡើងដែលយកមនុស្សជាស្នូល ដែលធ្វើឱ្យការបោះឆ្នោតងាយស្រួល ប្រសើរដល់អ្នកប្រើប្រាស់ និងអាចប្រើប្រាស់បានគ្រប់គ្នា៉។

បទពិសោធន៍ក្នុងការបោះឆ្នោតថ្មីនៅក្នុងខោនធី **Los Angeles** គឺត្រូវបានរៀបចំឡើងដើម្បីបង្កលក្ខណៈងាយស្រួល និងអាចប្រើប្រាស់បានសម្រាប់អ្នកបោះឆ្នោតគ្រប័គ្នា ។ ការផ្លាស់ប្តូរបែបបង្កើតថ្មីផ្តល់ឱ្យអ្នកបោះឆ្នោតគ្រប់គ្នា ដោយមិនគិតពីអាយុ សាវតារ ពិការភាព ឬភាសា នូវបទពិសោធន៍ក្នុងការបោះឆ្នោតដែលមានលក្ខណៈឯកជននិងឯករាជ្យ ដែលងាយស្រួលនិងស្រណុក ។

### ជម្រើសបត់បែន



អ្នកបោះឆ្នោតនឹងអាចបោះឆ្នោតនៅមណ្ឌលបោះឆ្នោតណាមួយក៏បាននៅទូទាំងខោនធីសម្រាប់ពេលបោះឆ្នោតដែលមានរហូតដល់ 11 ថ្ងៃ ។ គ្រប់ឧបករណ៍បោះឆ្នោតនៅមណ្ឌលបោះឆ្នោតគឺអាចប្រើប្រាស់បានពេញលេញ ។

### សន្លឹកឆ្នោតគំរូបែបអន្តរកម្ម (ISB)



ISB គឺជាជម្រើសងាយស្រួលសម្រាប់អ្នកបោះឆ្នោតដែលចង់គូសទុកជាមុននូវជម្រើសរបស់ពួកគេនៅផ្ទះ ដោយប្រើប្រាស់ឧបករណ៍ផ្ទាល់ខ្លួនជាមួយគ្រឿងឧបករណ៍ដែលពួកគេជ្រើសរើស ។ ISB បង្កើតប័ណ្ណឆ្លងកាត់ការបោះឆ្នោត (Poll Pass) ដែលដូចគ្នានឹងប័ណ្ណឆ្លងកាត់ការឡើងជិះយន្តហោះដែរ ។ នៅមណ្ឌលបោះឆ្នោត អ្នកបោះឆ្នោតស្កេនប័ណ្ណឆ្លងកាត់ការបោះឆ្នោតដើម្បីផ្ទេរជម្រើសនានារបស់ពួកគេទៅ BMD ។ បន្ទាប់មក ពួកគេអាចពិនិត្យមើលឡើងវិញនិងកែប្រែការបោះឆ្នោតរបស់ពួកគេ មុននឹងបោះសន្លឹកឆ្នោតរបស់ពួកគេ ។

### ឧបករណ៍គូសសន្លឹកឆ្នោត (BMD)



BMD ធ្វើឱ្យងាយស្រួលសម្រាប់អ្នកបោះឆ្នោតក្នុងការកែសម្រួលបទពិសោធន៍ក្នុងការបោះឆ្នោតឱ្យត្រូវតាមតម្រូវការរបស់ពួកគេ ។ អ្នកបោះឆ្នោតអាចកែតម្រូវការកំណត់នានានៅលើ BMD រួមទាំងកម្រិតពន្លឺនៃផ្ទាំងអ្នកប្រើប្រាស់ (user interface) ទំហំអត្ថបទ មុំអេក្រង់ ព្រមទាំងកម្រិតសំឡេងនិងល្បឿន ។

ម៉ូដចំនួនបួននៃផ្ទាំងអ្នកប្រើប្រាស់ធ្វើឱ្យងាយស្រួលសម្រាប់អ្នកបោះឆ្នោតទាំងអស់ដើម្បីបោះឆ្នោតជាលក្ខណៈឯកជននិងដោយឯករាជ្យ ។



**ការពាល់**

អន្តរអំពើជាមួយថាច់ស្គ្រីន (touchscreen)



**ការពាល់ + សំឡេង**

អន្តរអំពើជាមួយថាច់ស្គ្រីន និងស្តាប់ឮសេចក្តីណែនាំជាសំឡេងតាមរយៈកាសត្រចៀក



**ប្រដាប់បញ្ជារ + សំឡេង**

អន្តរអំពើជាមួយប្រដាប់បញ្ជារបែបកាយវិញ្ញាណដោយមានស្លាកជាអក្សរផុស និងខ្សែដែលអាចលៃតម្រូវបាន ហើយស្តាប់ឮសេចក្តីណែនាំជាសំឡេងតាមរយៈកាសត្រចៀក



**រន្ធដោតប្រភេទ A/B ឬរន្ធដោតពីរ**

អន្តរអំពើជាមួយឧបករណ៍ផ្ទាល់ខ្លួនរបស់អ្នក ។ ប្រើប្រាស់រន្ធដោតដែលមានសម្រាប់ឧបករណ៍បច្ចេកវិទ្យាជំនួយ មើលអន្តរកម្មនៅលើអេក្រង់ ហើយស្តាប់ឮសេចក្តីណែនាំជាសំឡេងតាមរយៈកាសត្រចៀក

# ខោនធី LA កំពុងតែធ្វើទំនើបកម្មនៃ បទពិសោធន៍ការបោះឆ្នោតនៅឆ្នាំ 2020

បទពិសោធន៍ការបោះឆ្នោតសំរាប់ខោនធី LA បច្ចុប្បន្ននេះ គឺចាស់ហួសសម័យ ហើយត្រូវការធ្វើទំនើបកម្មជាចាំបាច់បំផុត ។ អ្នកបោះឆ្នោតគួរតែអាចធ្វើការបោះឆ្នោតនៅពេលណា, នៅទីណានិងតាមរបៀបដែលគេចង់បាន ។ ប្រព័ន្ធបោះឆ្នោតថ្មីដែលកំពុងតែដំណើរការនៅក្រោម ដំណោះស្រាយក្នុងការបោះឆ្នោតសំរាប់ពលរដ្ឋគ្រប់រូប គឺជាជំហានដ៏មានសារៈសំខាន់មួយដើម្បីនឹងឈានទៅដល់ការសម្រេចបាននូវគោលដៅទាំងនេះ ។

## បច្ចុប្បន្ន ទល់និង អនាគត



- បទពិសោធន៍បោះឆ្នោតមានកម្រិត
- មានតែ 1 ថ្ងៃដើម្បីធ្វើការបោះឆ្នោត
- កន្លែងបោះឆ្នោត



- អ្នកបោះឆ្នោតណាក៏អាចប្រើប្រាស់បាន
- មាន 11 ថ្ងៃដើម្បីធ្វើការបោះឆ្នោត
- មជ្ឈមណ្ឌលបោះឆ្នោត

Inka Vote

សម្ភារៈបោះឆ្នោតហួសសម័យ ហើយមិនអាចប្រើប្រាស់បានសំរាប់អ្នកបោះឆ្នោតជាច្រើន, កម្រិតឧបករណ៍ 1 ក្នុងកន្លែងបោះឆ្នោតមួយ

បញ្ជីឈ្មោះអ្នកបោះឆ្នោតគឺត្រូវបានបោះពុម្ពទុកជាមុនដែលជាញឹកញាប់តម្រូវឲ្យមានការបោះពុម្ពបន្ថែម

LA ខោនធី

អ្នកបោះឆ្នោតអាចធ្វើការបោះឆ្នោតនៅឯមជ្ឈមណ្ឌលបោះឆ្នោត ណាមួយ ក៏បាននៅទូទាំងខោនធី ជាមួយនឹងសេវាកម្មផ្នែកភាសាពេញលេញនឹងលទ្ធភាពចូលប្រើប្រាស់ទូលំទូលាយ

*បញ្ជីឈ្មោះអ្នកបោះឆ្នោតជាទម្រង់អេឡិចត្រូនិចផ្តល់នូវទិន្នន័យ ទាន់សភាពការណ៍ពិតប្រាកដហើយអនុញ្ញាតឲ្យមានការចុះឈ្មោះបោះឆ្នោតក្នុងថ្ងៃតែមួយ

បោះឆ្នោតមុនពេល

**ទីកន្លែងបោះឆ្នោតមុនពេលដែលអាច ប្រើប្រាស់បានក្នុងខោនធីគឺមានកម្រិតចំនួន**

**មានឧបករណ៍អាចប្រើប្រាស់បានគ្រប់គ្រាន់ ដែលដាក់ជូននៅ គ្រប់មជ្ឈមណ្ឌលបោះឆ្នោត ។**

**អ្នកបោះឆ្នោតអាចបោះឆ្នោតបានតែ 1 កន្លែងតែប៉ុណ្ណោះ តែ 1 ថ្ងៃ នៅចន្លោះម៉ោង 7:00 ព្រឹក ដល់ 8:00 យប់**

11 ថ្ងៃ

**ការបោះឆ្នោតអាចធ្វើទៅបាន 11 ថ្ងៃ នៅ មជ្ឈមណ្ឌលបោះឆ្នោតទូទាំងខោនធី ។**

*ការបោះឆ្នោតគំរូថ្មីនឹងដឹកនាំឲ្យយើងចាកចេញពីការពឹងផ្អែកទៅលើ បញ្ជីឈ្មោះអ្នកបោះឆ្នោតដែលបានបោះពុម្ពទុកជាមុន ហើយជាជំនួសវិញនោះផ្តល់ជូននូវទិន្នន័យទាន់សភាពការណ៍ពិតប្រាកដរបស់អ្នកបោះឆ្នោតនៅគ្រប់ទីកន្លែងបោះឆ្នោត ដែលធ្វើឲ្យការចុះឈ្មោះបោះឆ្នោតក្នុងថ្ងៃតែមួយមានភាពងាយស្រួលឡើងទៀត ។

សំរាប់ព័ត៌មានបន្ថែម, សូមចូលទៅ **VSAP.lavote.net**

# ដំណោះស្រាយក្នុងការបោះឆ្នោតសំរាប់ពលរដ្ឋគ្រប់រូប

# បោះឆ្នោតតាមសំបុត្រ៖ អ្វីដែលលោកអ្នកត្រូវដឹង

ខោនធី Los Angeles បានរចនាឡើងវិញនូវសម្ភារៈបោះឆ្នោតតាមសំបុត្រ ដើម្បីធ្វើអោយកាន់តែងាយស្រួលនិងស្រណុកក្នុងការបោះឆ្នោតតាមសំបុត្រ ។ ការបោះឆ្នោតសាកល នៅថ្ងៃទី 6 ខែវិច្ឆិកា ឆ្នាំ 2018 គឺជា លើកដំបូងដែលអ្នកបោះឆ្នោតតាមសំបុត្រនឹងទទួលបានសម្ភារៈដែលត្រូវបានរចនាឡើងវិញទាំងនេះ ។

## អ្វីខ្លះដែលថ្មី?

### ប័ណ្ណសន្លឹកឆ្នោតនិងស្រោមសំបុត្រថ្មី

- សន្លឹកឆ្នោតពេញផ្ទៃមុខ
- ងាយស្រួលអានជាងមុន
- ងាយស្រួលបំពេញជាងមុន
- ងាយស្រួលយល់ជាងមុន

### ជម្រើសបញ្ជូនត្រឡប់វិញ?

អ្នកអាចបញ្ជូនសន្លឹកឆ្នោតបោះតាមសំបុត្ររបស់អ្នកត្រឡប់មកយើងខ្ញុំវិញតាម រយៈ USPS ។ **មិនចាំបាច់ប្រើតែមប្រៃសនីយ៍នោះទេ ។** លើសពីនេះទៀតអ្នកអាចទម្លាក់វានៅទីតាំងបោះឆ្នោតណាមួយក៏បានឬក៏នៅទីកន្លែងទម្លាក់សន្លឹកឆ្នោតថ្មីហើយងាយស្រួលមួយរបស់យើងខ្ញុំ ស្ថិតនៅទូទាំងខោនធី LA ។

### សន្លឹកឆ្នោតជាពហុភាសា

យើងខ្ញុំផ្តល់ជូនសន្លឹកឆ្នោតជាភាសាផ្សេងៗ 12 ភាសា។ សូមទូរស័ព្ទមកការិយាល័យយើងខ្ញុំដើម្បីស្នើសុំសន្លឹកឆ្នោតពហុភាសារបស់អ្នក តាមរយៈ: លេខ **(800) 815-2666, ជម្រើស 3**




តើអ្នកដឹងថាវាចេញមកពីខាងយើងខ្ញុំបានយ៉ាងដូចម្តេច?

សូមចូលទៅកាន់ LAvote.net ដើម្បីស្នើសុំសន្លឹកឆ្នោតបោះតាមសំបុត្រ, ស្វែងរកទីតាំងទម្លាក់សន្លឹកឆ្នោតបោះតាមសំបុត្រ ឬតាមដានសន្លឹកឆ្នោតបោះតាមសំបុត្ររបស់អ្នក ។

# ដំណោះស្រាយក្នុងការបោះឆ្នោតសំរាប់ពលរដ្ឋគ្រប់រូប

## សំណួរដែលគេសួរជាញឹកញាប់អំពី ការបោះឆ្នោតតាមសំបុត្រ

### ហេតុអ្វីមានការផ្លាស់ប្តូរ?

▲ ដើម្បីធ្វើឲ្យបទពិសោធន៍ក្នុងការបោះឆ្នោតរបស់លោកអ្នកមានភាពប្រសើរឡើងថែមទៀត ងាយស្រួលនិងអាចប្រើប្រាស់បាន ។ សន្លឹកឆ្នោតនឹងមានភាពងាយស្រួលក្នុងការអាននិងងាយស្រួលក្នុងការធ្វើជម្រើសបោះឆ្នោតរបស់លោកអ្នក ។ ការបោះឆ្នោតសាកលថ្ងៃទី 6 ខែវិច្ឆិកា ឆ្នាំ 2018 គឺជាការបោះឆ្នោតលើកទីមួយ ដែលអ្នកបោះឆ្នោតទទួលបាននូវសម្ភារៈថ្មីនៃការបោះឆ្នោតតាមសំបុត្រ (VBM) របស់ពួកគេ ។




### តើសន្លឹកឆ្នោត VBM ថ្មីមានលក្ខណៈដូចម្តេច ?

▲ សម្ភារៈសំរាប់ការបោះឆ្នោតតាមសំបុត្រ VBM រួមមានប័ណ្ណសន្លឹកឆ្នោតពេញផ្ទៃមុខដែលផ្ទុកនូវព័ត៌មានចាំបាច់នានា ដែលត្រូវការដើម្បីធ្វើការបោះឆ្នោត ។ អាស្រ័យទៅតាមទំហំនៃការបោះឆ្នោតនិងចំនួននៃការប្រកួតប្រជែងនៅលើសន្លឹកឆ្នោត, កញ្ចប់ VBM អាចនឹងផ្ទុកនូវប័ណ្ណជាច្រើនដែលមានការប្រកួតប្រជែងនៅខាងមុខនិងខាង ក្រោយ (សូមមើលគំរូនៅខាងស្តាំ) ។

បើលោកអ្នកស្នើសុំសម្ភារៈបោះឆ្នោតជាភាសាផ្សេងក្រៅពីភាសាអង់គ្លេស នោះ, លោកអ្នកនឹងទទួលបានសន្លឹកឆ្នោតបោះតាមសំបុត្រ VBM មួយជាភាសាដែលលោកអ្នកបានស្នើសុំរួមជាមួយនឹងអត្ថបទជាភាសាអង់គ្លេសផងដែរ ដើម្បីជាជំនួយដល់លោកអ្នកក្នុងការបោះឆ្នោត ។

### តើតែមប្រៃសនីយ៍ប៉ុន្មានដែលខ្ញុំត្រូវការដើម្បីផ្ញើសន្លឹកឆ្នោតរបស់ខ្ញុំតាមសេវាប្រៃសនីយ៍សហរដ្ឋ (USPS)?

▲ គ្មានទេ ។ តែមត្រូវបានបង់ថ្លៃឲ្យមុនរួចជាស្រេចសំរាប់អ្នកបោះឆ្នោតតាមសំបុត្រទាំងអស់ក្នុងខោនធី Los Angeles ។

### តើខ្ញុំអាចបញ្ជូនត្រឡប់សន្លឹកឆ្នោត VBM របស់ខ្ញុំទៅវិញដោយរបៀបណា ?

▲ អ្នកអាចបញ្ជូនត្រឡប់សន្លឹកឆ្នោត VBM របស់អ្នកទៅវិញតាមរយៈ USPS (សេវាប្រៃសនីយ៍សហរដ្ឋ), គ្រាន់តែទម្លាក់វាទៅក្នុងប្រអប់សំបុត្រ, មិនតម្រូវឲ្យបិទតែមនោះទេ ។ បើអ្នកចង់បញ្ជូនវាដោយផ្ទាល់មកយើងខ្ញុំ អ្នកអាចទម្លាក់វានៅទីកន្លែងទម្លាក់សន្លឹកឆ្នោតណាមួយក៏បាន នៅថ្ងៃបោះឆ្នោត ។ មិនថាអ្នកបញ្ជូនត្រឡប់វាទៅវិញតាមរបៀបណានោះទេ, សូមកុំភ្លេចចុះហត្ថលេខានិងកាលបរិច្ឆេទនៅលើស្រោមសំបុត្របញ្ជូនត្រឡប់វិញរបស់អ្នក ។

### តើសន្លឹកឆ្នោត VBM ចាប់ផ្តើមផ្ញើតាមសំបុត្រនៅពេលណា ?

▲ យើងខ្ញុំចាប់ផ្តើមផ្ញើរចេញសន្លឹកឆ្នោត VBM 29 ថ្ងៃមុនថ្ងៃបោះឆ្នោត ។ អ្នកបោះឆ្នោតដែលបានចុះឈ្មោះជា VBM អចិន្ត្រៃយ៍ នឹងចាប់ផ្តើមទទួលបានសន្លឹកឆ្នោតរបស់ពួកគេប៉ុន្មានថ្ងៃបន្ទាប់ពីការផ្ញើតាមសំបុត្រ ។ ការស្នើសុំតែមួយដងនឹងត្រូវបានដំណើការប្រចាំថ្ងៃ ហើយគួរទទួលបានក្នុងរយៈពេលប៉ុន្មានថ្ងៃបន្ទាប់ពីការស្នើសុំ ។

### តើខ្ញុំត្រូវការអ្វីដើម្បីបំពេញសន្លឹកឆ្នោត VBM ?

▲ សន្លឹកឆ្នោត VBM ត្រូវតែបំពេញដោយប្រើទឹកប៊ិចពណ៌ខ្មៅ ឬខៀវ ។

### តើស្រោមសំបុត្រ VBM ថ្មីមានលក្ខណៈដូចម្តេច ?

▲ ស្រោមសំបុត VBM ដែលចេញដោយការិយាល័យមន្ត្រីចុះបញ្ជីរបស់ខោនធី Los Angeles នឹងមានបង្ហាញសេចក្តីជូនដំណឹងនៅខាងមុខរបស់ស្រោមសំបុត្រៈ សំបុត្រការបោះឆ្នោតផ្លូវការដែលអនុញ្ញាតដោយ សេវាប្រៃសនីយ៍សហរដ្ឋ ។ បន្ថែមពីលើនេះ, អ្នកនឹងឃើញត្រារបស់ខោនធីនៅលើគ្រប់ស្រោមសំបុត្រ ។ សម្រាប់សំណួរឬកង្វល់នានាពាក់ព័ន្ធទៅនឹង VBM, សូមទូរស័ព្ទទៅលេខ 1-800-815-2666, ជម្រើស 2 ។

# ដំណោះស្រាយក្នុងការបោះឆ្នោតសំរាប់ពលរដ្ឋគ្រប់រូប

## សំណួរដែលគេសួរជាញឹកញាប់អំពី ការបោះឆ្នោតតាមសំបុត្រ

**តើខ្ញុំត្រូវផ្ញើត្រឡប់មកវិញនូវប័ណ្ណសន្លឹកឆ្នោតទាំងអស់ ដើម្បីឲ្យជម្រើសរបស់ខ្ញុំត្រូវបានរាប់?**

យើងខ្ញុំសូមឲ្យអ្នកផ្ញើមកវិញគ្រប់ប័ណ្ណសន្លឹកឆ្នោតទាំងអស់ ។ តែយ៉ាងណាក៏ដោយ, បើមិនបានផ្ញើមកវិញគ្រប់ប័ណ្ណសន្លឹកឆ្នោតទាំងអស់នោះទេ ក៏មិនមានផលប៉ះពាល់អ្វីឡើយ សំរាប់ការបោះឆ្នោតលើប័ណ្ណសន្លឹកឆ្នោតដែលអ្នកបានផ្ញើត្រឡប់មកវិញ ។

**តើខ្ញុំគួរធ្វើអ្វី បើខ្ញុំធ្វើឲ្យខូចឬបាត់ប័ណ្ណសន្លឹកឆ្នោត VBM របស់ខ្ញុំ?**

បើអ្នកធ្វើឲ្យខូចឬបាត់ប័ណ្ណសន្លឹកឆ្នោតរបស់អ្នកមួយឬច្រើន អ្នកអាចស្នើសុំសម្ភារៈប្តូរថ្មីរហូតដល់ 7 ថ្ងៃមុនដល់ថ្ងៃបោះ ឆ្នោត។ បើការប្តូរថ្មីមួយត្រូវបានស្នើសុំ យើងខ្ញុំនឹងផ្ញើជូនកញ្ចប់ VBM ថ្មីស្រឡាង ។ បើមានរយៈពេលតិចជាង 7 ថ្ងៃមុនថ្ងៃបោះឆ្នោតនោះ សូមទាក់ទងការិយាល័យយើងខ្ញុំតាមរយៈលេខ (800) 815-2666, ជម្រើស 2 ។

**តើខ្ញុំអាចស្នើសុំសន្លឹកឆ្នោត VBM ដោយរបៀបណា?**

អ្នកអាចស្នើសុំសន្លឹកឆ្នោត VBM តាមអ៊ីនធឺណិតនៅលើគេហទំព័រ **LAvote.net** ឬដោយបំពេញក្រុបខាងក្រោយនៃកូនសៀវភៅសន្លឹកឆ្នោតគំរូ ហើយបញ្ជូនវាត្រឡប់ទៅការិយាល័យមន្ត្រីចុះបញ្ជីខោនធី Los Angeles វិញ ។

**តើខ្ញុំស្នើសុំសន្លឹកឆ្នោត VBM ជាភាសាផ្សេងពីភាសាអង់គ្លេសដោយរបៀបណា?**

សូមទូរស័ព្ទទៅផ្នែកសេវាពហុភាសារបស់មន្ត្រីចុះបញ្ជីរបស់ខោនធី Los Angeles តាមរយៈលេខ (800) 815-2666, ជម្រើស 3 ដើម្បីស្នើសុំសម្ភារៈការបោះឆ្នោតជាភាសាមួយផ្សេងទៀត ។

**តើខ្ញុំគួរធ្វើអ្វីជាមួយនឹងឈុតសម្ភារៈ VBM ដំបូងរបស់ខ្ញុំ បើខ្ញុំបានស្នើសុំឈុតថ្មីហើយនោះ ?**

សូមសរសេរ "មោឃៈ" (Void) នៅលើសម្ភារៈចាស់ទាំងអស់ ហើយបោះពួកវាចោល ។

**តើមានអ្វីកើតឡើង បើហត្ថលេខានៅលើស្រោមសំបុត្របញ្ជូនត្រឡប់វិញមិនមាន ឬមិនត្រូវគ្នានឹងហត្ថលេខានៅលើឯកសារតម្កល់ ។**

ការិយាល័យមន្ត្រីចុះបញ្ជីខោនធី Los Angeles នឹងផ្ញើតាមសំបុត្រនូវទម្រង់ពាក្យសម្បថសន្លឹកឆ្នោតដែលមិនទាន់ចុះហត្ថលេខាដើម្បីឲ្យអ្នកបំពេញនិងចុះហត្ថលេខា។ អ្នកនឹងមានពេលរហូតដល់ទៅ 8 ថ្ងៃបន្ទាប់ពីថ្ងៃបោះឆ្នោត ដើម្បីបញ្ជូនត្រឡប់នូវទម្រង់ពាក្យនោះទៅការិយាល័យរបស់យើងខ្ញុំដើម្បីឲ្យសន្លឹកឆ្នោតរបស់អ្នកត្រូវបានគេរាប់ ។

**តើខ្ញុំអាចតាមដានសន្លឹកឆ្នោត VBM បានដែរឬទេ?**

បាន, ដូចដែលដំណើរការ VBM បច្ចុប្បន្នរបស់យើងខ្ញុំដែរ អ្នកបោះឆ្នោតអាចតាមដានសន្លឹកឆ្នោតរបស់ពួកគេតាមអ៊ិនធើណែតនៅលើគេហទំព័រ LAvote.net ។

**តើខ្ញុំអាចស្វែងយល់បន្ថែមអំពីបទពិសោធន៍ VBM ថ្មីនៅកន្លែងណា ?**

សូមចូលទៅកាន់ VSAP.lavote.net ដើម្បីស្វែងយល់បន្ថែមអំពីការស្រាវជ្រាវ និងការរៀបចំដែលបានបញ្ចូលទៅក្នុងបទពិសោធន៍ VBM ថ្មីនោះ ។

# ដំណោះស្រាយក្នុងការបោះឆ្នោតសំរាប់ពលរដ្ឋគ្រប់រូប

## ការប្រៀបធៀបសុវត្ថិភាព

**BMD** ឧបករណ៍គូស សន្លឹកឆ្នោត **ធៀបនឹង** **DRE** ប្រព័ន្ធអេឡិចត្រូនិច កត់ត្រាដោយផ្ទាល់

**លក្ខណៈសុវត្ថិភាពចម្បងនៃ BMD ធៀបនឹង DRE គឺថាវាផ្តល់នូវសន្លឹកឆ្នោតក្រដាសដែលអាចឱ្យមនុស្សអានបាន**

| សន្លឹកឆ្នោតក្រដាស | សន្លឹកឆ្នោតអេឡិចត្រូនិច |
| --- | --- |
| អាចឱ្យមនុស្សអានបានសម្រាប់អ្នកបោះឆ្នោតធ្វើការផ្ទៀងផ្ទាត់ សវនកម្ម និងរាប់ឡើងវិញ | ការកត់ត្រាបែបអរូបិយនៃបំណងអ្នកបោះឆ្នោតដែលមិនអាចឱ្យអ្នកបោះឆ្នោតផ្ទៀងផ្ទាត់ដោយងាយស្រួល |
| គាំទ្រដល់ភាពអាចធ្វើសវនកម្មបាននៅគ្រប់ដំណាក់កាល ចាប់ពីសន្លឹកឆ្នោតក្រដាសរហូតដល់ការកត់ត្រាចំនួនការបោះឆ្នោតដែលត្រូវបានបូកសរុប | លទ្ធភាពមានកម្រិតក្នុងការធ្វើសវនកម្មដោយសន្លឹកឆ្នោតត្រូវបានរាប់នៅពេលបោះ |
| ត្រូវបានបូកសរុបជាលក្ខណៈកណ្តាលក្នុងកន្លែងសុវត្ថិភាពនៅលើប្រព័ន្ធរៀបជាតារាងការបោះឆ្នោត | ការបូកសរុបលើឧបករណ៍មូលដ្ឋានបង្កហានិភ័យដល់សុវត្ថិភាព |
| សន្លឹកឆ្នោតមិនត្រូវបានរក្សាទុកជាលក្ខណៈអេឡិចត្រូនិចនៅលើឧបករណ៍ឡើយ ។ ខ្សែចង្វាក់នៃការមើលថែរក្សាច្បាស់លាស់ | សន្លឹកឆ្នោតត្រូវបានរក្សាទុកជាលក្ខណៈអេឡិចត្រូនិចនៅលើឧបករណ៍។ បង្កើនហានិភ័យក្នុងការផ្ទេរទិន្នន័យ |
| មិនអាចត្រូវបានកែប្រែដោយគ្មានការតាមដានដឹង | អាចពិបាកក្នុងការតាមដានដឹងការបូកសរុបនិងសន្លឹកឆ្នោតដែលត្រូវបានកែប្រែ |

# ដំណោះស្រាយក្នុងការបោះឆ្នោតសំរាប់ពលរដ្ឋគ្រប់រូប

## សុវត្ថិភាព

ផ្តល់ជូនអ្នកបោះឆ្នោតនៅខោនធី Los Angeles នូវបទពិសោធន៍ក្នុងការបោះឆ្នោតដែលមានសុវត្ថិភាព ត្រឹមត្រូវ និងតម្លាភាព ។

បទពិសោធន៍ក្នុងការបោះឆ្នោតថ្មីនៅក្នុងខោនធី Los Angeles ត្រូវបានរៀបចំឡើងដើម្បីសុវត្ថិភាព និងតម្លាភាពសម្រាប់អ្នកបោះឆ្នោតគ្រប់គ្នា ។ មានធាតុផ្សំជាច្រើននៃប្រព័ន្ធនេះដែលការពារសេចក្តីសុចរិតនៃការបោះឆ្នោត និងដំណើរការនៃការបោះឆ្នោត ។

### ការរៀបចំដែលមានសុវត្ថិភាព



ឧបករណ៍គូសសន្លឹកឆ្នោត (BMD) បោះពុម្ពសន្លឹកឆ្នោតក្រដាសដែលអ្នកបោះឆ្នោតអាចផ្ទៀងផ្ទាត់បាន ។ ជម្រើសរបស់អ្នកបោះឆ្នោតត្រូវបានបោះពុម្ពក្នុងទម្រង់ជាអត្ថបទដែលអាចឱ្យមនុស្សអានបាន និងជាកំណត់ត្រាការបោះឆ្នោតផ្លូវការ ។ តាមរយៈការរៀបចំនេះ BMD មិនត្រូវបានភ្ជាប់ទៅកាន់បណ្តាញណាមួយ ឬអ៊ីនធឺណិតឡើយ ។ វាមិនរក្សាទុកនូវទិន្នន័យរបស់អ្នកបោះឆ្នោត ឬចំនួនការបោះឆ្នោតសរុបឡើយ។

### ឯកជនភាព និងការរក្សាការសម្ងាត់



ព័ត៌មានរបស់អ្នកបោះឆ្នោតនៅលើបញ្ជីបោះឆ្នោតអេឡិចត្រូនិច (E-pollbooks) មិនត្រូវបានភ្ជាប់ទៅនឹង BMD ឬប្រព័ន្ធបូកសរុបការបោះឆ្នោតឡើយ ។ បញ្ជីទាំងនេះនៅឯករាជ្យពីគ្នាដើម្បីការពារព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកបោះឆ្នោត ។ សន្លឹកឆ្នោតដែលបានបោះពុម្ពមិនមានព័ត៌មានរបស់អ្នកបោះឆ្នោតទេ ។

### ការត្រួតពិនិត្យសិទ្ធិប្រើប្រាស់ពហុលក្ខណៈ



ការិយាល័យអ្នកចុះបញ្ជីនៃខោនធី Los Angeles រក្សានូវរបៀបរបបសុវត្ថិភាពសមស្របនៅដំណាក់កាលនីមួយៗក្នុងដំណើការនៃការបោះឆ្នោត ។ បុគ្គលិកបោះឆ្នោតមានព័ត៌មានសម្ងាត់របស់អ្នកប្រើប្រាស់ជាក់លាក់ ដើម្បីកាត់បន្ថយភាពដែលអាចកើតមានលើការប្រើប្រាស់ដែលគ្មានការអនុញ្ញាត ។ ការប្រើប្រាស់សោរនិងត្រាសម្គាល់ដើម្បីការពារការរុះរើនៅលើហិបឆ្នោតដែលមានលក្ខណៈរួមបញ្ចូល (IBB) ហើយគ្រឿងបរិក្ខារការបោះឆ្នោតដែលឆាប់ញោច ការពារបាននូវសេចក្តីសុចរិតនៃការបោះឆ្នោតនិងធានាបាននូវខ្សែចង្វាក់នៃការរក្សាទុកដែលអាចផ្ទៀងផ្ទាត់បាន ។

### តម្លាភាព និងលទ្ធភាពចេញចូល



បទពិសោធន៍ក្នុងការបោះឆ្នោតថ្មីបានរួមបញ្ចូលនូវការការពារចាំបាច់ប្រឆាំងនឹងភាពទន់ខ្សោយរបស់ប្រព័ន្ធ ព្រមទាំងធានាឱ្យបាននូវតម្លាភាព និងសិទ្ធិប្រើប្រាស់ជាសាធារណៈសម្រាប់ដំណើរការនៃការបោះឆ្នោត ដោយធ្វើសវនកម្មដោយផ្ទាល់ដៃលើសន្លឹកឆ្នោតដែលបានបោះចំនួន 1% ក្នុងរយៈពេលក្រោយការបោះឆ្នោត មុននឹងធ្វើការបញ្ជាក់។

# ដំណោះស្រាយក្នុងការបោះឆ្នោតសំរាប់ពលរដ្ឋគ្រប់រូប

## លក្ខណៈរបស់មន្ទីរមជ្ឈមណ្ឌលបោះឆ្នោត

### ទិដ្ឋភាពទូទៅនៃមជ្ឈមណ្ឌលបោះឆ្នោតគំរូ

នៅឆ្នាំ 2020, ខោនធី Los Angeles នឹងផ្លាស់ប្តូរទៅជាការបោះឆ្នោតគំរូថ្មីមួយ ដែលអាចឲ្យអ្នកបោះឆ្នោតទាំងឡាយបោះឆ្នោតនៅទីកន្លែងបោះឆ្នោតណាក៏បានក្នុងខោនធី ។

- **មជ្ឈមណ្ឌលបោះឆ្នោត**ដែលងាយស្រួល, មានសុវត្ថិ ភាព ហើយចេញចូលបានមានដាក់ជូនប្រើប្រាស់ចំនួន 11 ថ្ងៃ ។
- **ទីកន្លែងប្រអប់ទម្លាក់សន្លឹកឆ្នោតបោះតាមប្រៃសនីយ៍**មានដាក់ជូនចំនួន 29 ថ្ងៃ
- **ការចុះឈ្មោះអ្នកបោះឆ្នោតក្នុងថ្ងៃតែមួយ**ត្រូវបានអនុញ្ញាត
- **សន្តិសុខ**ដែលប្រកបទៅដោយ**បច្ចេកវិទ្យា**បែបថ្មៃប្រឌិតនិងមានកម្រិតខ្ពស់
- **បុគ្គលិកនៅនឹងកន្លែង**សំរាប់ផ្តល់ជំនួយជាពហុភាសា

### តម្រូវការស្តីពីច្បាប់សំរាប់ភាពងាយស្រួលចេញចូលបានសំរាប់ជនជាតិអាមេរិកាំងដែលមានពិការភាព (ADA)

គ្រប់មន្ទីរទាំងអស់ត្រូវតែសមស្របទៅតាមតម្រូវការរបស់ ADA រួមមាន៖

- ផ្លូវដែលចេញចូលបានសំរាប់ការធ្វើដំណើរពី ផ្លូវ/ការដឹកជញ្ជូនសាធារណៈទៅដល់មុខទ្វារតាម ADA
- មាត់ទ្វារដែលមានទទឹងប្រវែង 32"
- បន្ទប់ទឹកដែលបានកំណត់តាម ADA
- ទីចំណតនៅនឹងកន្លែងដែលបានកំណត់តាម ADA
- មិនត្រូវមានអ្វីនៅខាងក្នុង ដែលអាចជាឧបស័គ្គរាំងរាដល់ដំណើរការសំរាប់រទេះរុិលកង់ឡើយ



### ថាមពលនិងការភ្ជាប់អ៊ិនធើណែត

គ្រប់បន្ទប់ទាំងអស់ លើកលែងតែបន្ទប់ផ្ទុកអីវ៉ាន់ នឹងត្រូវការកន្លែងត ថាមពលអគ្គីសនីនិងអ៊ិនធើណែត ។

ការភ្ជាប់ទៅអ៊ិនធើណែតអាចជា៖

- ខ្សែតភ្ជាប់រឹង Hard wired (DSL, Cable, Fiber)
- ប្រព័ន្ធ Wi-Fi
- ប្រព័ន្ធភ្ជាប់កុំព្យូទ័រទៅអ៊ិនធើណែតចល័តឥតខ្សែ (LTE, 4G)



### ករណីយ៍ដ៏ទៃទៀតដែលគួរពិចារណាសំរាប់គុណសម្បត្តិគ្រប់គ្រាន់

- ចំណតដែលអាចប្រើប្រាស់បាននៅនឹងកន្លែង
- ការដឹកជញ្ជូនសាធារណៈដែលងាយស្រួលប្រើប្រាស់បាន
- ម៉ោងពេលប្រតិបត្តិការដែលសមស្រប
- បន្ទប់ដែលមានទ្វារចាក់សោរបាន



# ដំណោះស្រាយក្នុងការបោះឆ្នោតសំរាប់ពលរដ្ឋគ្រប់រូប

## លក្ខណៈរបស់មន្ទីរមជ្ឈមណ្ឌលបោះឆ្នោត

### ទំហំអប្បបរិមាផ្ទៃខាងក្នុង

ទីកន្លែងអាចជាបន្ទប់ធំមួយឬក៏ច្រើន, ជាការល្អគឺបន្ទប់ជាប់ៗគ្នា ។ **មជ្ឈមណ្ឌលបោះឆ្នោតកើតឡើងដោយតំបន់ផ្សេងៗ ចំនួន 6 រួមផ្សំគ្នា៖**

- ជួរអ្នកបោះឆ្នោត/តំបន់តម្រង់ជួរ
- តំបន់ចុះឈ្មោះ
- តំបន់ឧបករណ៍គូសសន្លឹកឆ្នោត
- តំបន់បោះឆ្នោតតាមប្រៃសណីយ៍
- តំបន់សម្រាប់កញ្ចូស (kiosk)
- តំបន់ផ្ទុកអីវ៉ាន់

តំបន់ផ្សេងៗទាំងនេះគួរតែស្ថិតនៅក្នុងបន្ទប់តែមួយ ក៏ប៉ុន្តែតំបន់សំរាប់ផ្ទុកអីវ៉ាន់និង តំបន់ជួរ/តម្រង់ជួរ អាចនៅដាច់ដោយឡែកពីគ្នាក៏បាន ។

**តម្រូវការទំហំប្រហាក់ប្រហែលជាហ្វូតការ៉េដូចដែលបានបង្ហាញខាងក្រោមនេះ** អាចយកជាការបានដោយបូកបញ្ចូលនូវទំហំនៃតំបន់ដាច់ពីគ្នា/តំបន់ផ្សេងៗ ដែលបានបញ្ជាក់ពីខាងលើ ។

ទំហំនៃមន្ទីរ

**តូច**
1,050 ហ្វីតការ៉េ *

**មធ្យម**
2,450 ហ្វីតការ៉េ *

**ធំ**
3,850 ហ្វីតការ៉េ *

* ទំហំជាហ្វូតការ៉េគឺជាទំហំប្រហាក់ប្រហែលប៉ុណ្ណោះ



គំរូនៃការកំណត់រចនាសម្ព័ន្ធរបស់មជ្ឈមណ្ឌលបោះឆ្នោតធំ

# ដំណោះស្រាយក្នុងការបោះឆ្នោតសំរាប់ពលរដ្ឋគ្រប់រូប

## គម្រោងរៀបចំដាក់មជ្ឍមណ្ឌលបោះឆ្នោត

ក្នុងឆ្នាំ 2020 ខោនធី Los Angeles នឹងផ្លាស់ប្តូរពីការិយាល័យបោះឆ្នោតទៅជាមជ្ឍមណ្ឌលបោះឆ្នោត ។ ដើម្បីធានាថាទីកន្លែងទាំងនេះគឺអាចចេញចូលបានងាយស្រួលសម្រាប់អ្នកបោះឆ្នោត ខោនធីបានចាប់ដៃគូជាមួយអ្នកជំនាញៗដើម្បីធ្វើគម្រោងរៀបចំដាក់មជ្ឍមណ្ឌលបោះឆ្នោត ។

### អ្វីដែលយើងខ្ញុំកំពុងធ្វើ

ខោនធី LA នឹងធ្វើការវិភាគដែលទាក់ទងនឹងទីតាំង (spatial analysis) ដោយគ្រប់ជ្រុងជ្រោយដើម្បីដឹងថាពេលណានិងទីកន្លែងណាដែលអ្នកបោះឆ្នោតទំនងបំផុតនឹងទៅបោះឆ្នោត ។




លទ្ធភាពចេញចូល | សន្តិសុខ | ភាពជិតៗគ្នា | ភាពងាយស្រួល | ភាពមានបម្រុង

### របៀបដែលយើងខ្ញុំសម្រេចឱ្យបាន

ដើម្បីធានាថាតម្រូវការរបស់សហគមន៍ត្រូវបានដោះស្រាយ ខោនធីនឹង ៖

- ធ្វើការដោយផ្ទាល់ជាមួយក្រុមអ្នកប្រឹក្សាយោបល់ពលរដ្ឋ
- រៀបចំការប្រជុំភាគីពាក់ព័ន្ធ
- ធ្វើការស្ទង់មតិសហគមន៍
- ផ្តល់វេទិកាលើបណ្តាញអ៊ីនធឺណិតបែបអន្តរកម្មដើម្បីប្រមូលមតិយោបល់របស់សហគមន៍




### អ្វីដែលអ្នកបោះឆ្នោតទទួលបាន

- បទពិសោធន៍បោះឆ្នោតថ្មីមួយ
- មជ្ឍមណ្ឌលបោះឆ្នោតដែលងាយស្រួល សុវត្ថិភាព និងអាចចេញចូលបានងាយ មានផ្តល់ជូន 11 ថ្ងៃ
- ទីតាំងប្រអប់ទម្លាក់សន្លឹកឆ្នោតបោះតាមសំបុត្រមានផ្តល់ជូន 29 ថ្ងៃ
- មជ្ឍមណ្ឌលបោះឆ្នោតចល័ត និងដំឡើងភ្លាមៗ
- ភាពបត់បែនក្នុងការបោះឆ្នោតនៅទីតាំងណាក៏បានក្នុងខោនធី

